# ៣.រឿង ពស់កេងកង

កាលពីព្រេងនាយ មានចចកគ្រោសធំមួយ ដល់ខែលំហើយ វាដើររកត្រពាំងបឹងបួដែលរីងទឹក ដើម្បីចាប់ត្រីស៊ី ។ លុះទៅដល់ត្រពាំងមួយរីងទឹកអស់ នៅតែប្រទ្បង់មួយឃើញសុទ្ធតែភក់ មានត្រី កំពឹស បង្កង ក្តាម ជាច្រើនណាស់ ។ ចចកឃើញហើយមានចិត្តត្រេកអររីករាយគិតថា «ថ្ងៃនេះអញមានលាភធំណាស់ ជាលាភចម្លែកជាងសព្វថ្ងៃ» ។ ឯកំពឹសមានប្រាជ្ញា ឮចចកថាដូច្នោះហើយ ក៏និយាយលួងលោមចចកថា «យើងទាំងអស់គ្នាសុទ្ធតែចំណីបងចចកឯងទាំងអស់ហើយ ប៉ុន្តែយើងប្រទ្បាក់ភក់ណាស់ បងឯងស៊ីយើងទាំងភក់ដូច្នេះ មិនឆ្ងាញ់ពិសាទេ» ។ ចចកឆ្លើយថា «ធ្វើដូចម្តេចនឹងឆ្ងាញ់ពិសា ?» ។ កំពឹសឆ្លើយថា «ត្រូវបងចចកយកយើងទៅលាងទឹកឲ្យជ្រះស្អាតហើយសឹមស៊ីនោះទើបឆ្ងាញ់ពិសា» ។ ចចកថា «ដូចម្តេចនឹងយកទៅលាងបានបើច្រើនដល់ម្ល៉េះ?»។ កំពឹសថា «បងចចកកុំព្រួយចិត្ត ខ្ញុំធានាគិតឲ្យបងបានស្រួលប៉ុន្តែត្រូវបងឯងតាមខ្ញុំ»។ ចចកឆ្លើយឡើងថា «បងឯងធ្វើដូចម្តេចក៏ខ្ញុំតាមទាំងអស់» ។ កំពឹសថា «ធ្វើដូច្នេះចូរបងឯងចូលមកដេកននៀលក្នុងភក់នេះ ហើយយើងរាល់គ្នានឹងបានតោងខាំរោមបងឯង បងឯងនាំយើងទៅរកស្ទឹងបឹងបួឯណា ដែលមានទឹកថ្លាច្រើន បងឯងលាងយើងឲ្យស្អាត ហើយសឹមបងឯងស៊ីឆ្ងាញ់ពីសាតាមចិត្តចុះ» ។ ឯចចកជាសត្វលោភហើយល្ងង់ ក៏ធ្វើតាមពាក្យកំពឹស ។ កំពឹសនិងត្រី ក៏បបួលគ្នាតោងរោមចចកទៅ លុះទៅដល់បឹងមួយធំវែង មានទឹកថ្លាល្អ ចចកដើរចុះទៅក្នុងទឹក អស់ត្រីកំពឹសលោតទៅក្នុងទឹក ហើយប្រាប់ថា «បងចចកឯងទៅជញ្ជូនមកឲ្យអស់សិន សឹមមកស៊ីឲ្យឆ្អែតតែម្តង យើងនៅចាំបងនៅទីនេះ» ។ ចចកក៏ទៅជញ្ជូនត្រីនិងកំពឹសមក លុះត្រាតែអស់ពីត្រពាំងនោះ ។ ពួកត្រី កំពឹស ក្តាម ខ្យង ដឹងថា ចចកជញ្ជូនអស់ហើយក៏នាំគ្នាមុជក្នុងទឹកបាត់អស់ទៅ ។ ឯចចក ដឹងថាកំពឹសបញ្ឆោតដូច្នេះហើយខឹងណាស់ ដើរទៅបបួលអស់សត្វធំ តូច ដំរី រមាសខ្លា គ្រប់ភាសាសត្វ ទាំងពស់ថ្លាន់ ពស់ធំ ពស់តូច ទាំងសត្វហើរ គ្មានសេសសល់ដល់តិច បបួលគ្នាមកបាចទឹកបឹងនោះឲ្យរីង និងបានចាប់ត្រីក្នុងបឹងនោះស៊ីឲ្យអស់ បានឲ្យពស់ថ្លាន់ធ្វើជាទំនប់អស់សត្វឯទៀតក៏បបួលគ្នាបាច ។ សត្វក្នុងបឹងដឹងថា ចចកបបួលគ្នាបាចទឹកឲ្យរីងទាំងបឹងភ័យណាស់ ក៏គិតគ្នាថា «យើងធ្វើម្តេចនឹងបានឲ្យសត្វទាំងអស់នេះលែងបាចទឹក?» កាលនោះត្រីក្រាញ់ឆ្លើយឡើងថា «ខ្ញុំឮគេនិយាយថាបងសុភាទន្សាយជាអ្នកមានប្រាជ្ញា ចេះដោះទុក្ខមនុស្សសត្វផង ជាច្រើនណាស់ហើយ បើដូច្នេះខ្ញុំនឹងទៅពឹងបងសុភាទន្សាយ ឲ្យមកជួយដោះទុក្ខអស់យើង» ។ ពួកត្រីគិតគ្នាហើយ ក៏ប្រើត្រីក្រាញ់ទៅអញ្ជើញសុភាទន្សាយ ។ ត្រីក្រាញ់ប្រឹងននៀលទៅលុះដល់ត្រូវថ្ងៃក៏ក្រៀមស្រកាអស់ ដល់យប់សុភាទន្សាយចេញមករកស៊ី បានឃើញត្រីក្រាញ់ននៀលដូច្នោះក៏សួរថា «បងត្រីក្រាញ់ទៅណា?»។ ត្រីក្រាញ់ឃើញសុភាទន្សាយហើយមានចិត្តត្រេកអរណាស់និយាយអង្វរថា បងសុភាទន្សាយអាណិតខ្ញុំត្បិតត្រីទាំងអស់ក្នុងបឹងគេប្រើខ្ញុំមក ឲ្យអញ្ជើញបងសុភាទន្សាយទៅត្បិតឮទាំងសត្វទាំងមនុស្សនិយាយថា បងជាអ្នកមានប្រាជ្ញា ចេះកាត់សេចក្តីដោះទុក្ខ បើអ្នកឯណាកើតទុក្ខបងតែងទៅជួយដោះទុក្ខគេមិនដែលខាន ឥឡូវមានដំរី ក្របី គោ រមាស រមាំង ប្រើស ក្តាន់ ជ្រូក ពស់ធំ ពស់តូច ទាំងសត្វហើរ គឺកុក ក្រៀល បង្កៀលខ្យង ទុង ទោម ក្អែកទឹក ប្រវឹក ស្មោញ ទាំងប៉ុន្មាន បានបបួលគ្នាមកបាចទឹកបឹងឲ្យរីងនឹងបានចាប់អស់ ត្រី អណ្តើក កន្ធាយ ស៊ីជាចំណីឲ្យអស់ពីបឹងនេះឯង ។ បើដូច្នេះ បងសុភាទន្សាយអាណិតជួយដោះទុក្ខអស់បងប្អូនខ្ញុំ ឲ្យបានរួចពីភ័យម្តងនេះ នឹងបានល្បីកេរ្តិ៍ឈ្មោះតទៅ អស់យើងនឹងតបគុណបងសុភា

ទន្សាយឯង យើងមិនភ្លេចគុណជរាបដល់អស់ជីវិត ។ ឯទន្សាយឮត្រីក្រាញ់និយាយអង្វរដូច្នោះក៏ឆ្លើយថា «បងត្រីក្រាញ់ទៅមុនចុះ ទៅប្រាប់អស់បងប្អូនកុំឲ្យភិតភ័យ ចាំខ្ញុំជួយដោះឲ្យរួចកុំមានចិត្តបារម្ភឡើយ» ។ ត្រីក្រាញ់ក៏ត្រឡប់ទៅវិញ ឯទន្សាយលុះព្រឹកព្រហាម ឡើងទៅមាត់បឹង ឃើញអស់សត្វកំពុងបាចទឹក ក៏យកស្លឹកឈើដែលដង្កូវស៊ីធ្លុះៗមកធ្វើជាសំបុត្រ ហើយស្រែកហៅអស់សត្វទាំងនោះថា នែ ! បងប្អូនទាំងអស់ចាំស្តាប់ខ្ញុំត្បិតព្រះឥន្ទលោកឲ្យខ្ញុំនាំសំបុត្រមកប្រាប់គ្រប់គ្នាថា «ព្រះឥន្ទ្រលោកមកកាច់ជើងត្រុំ ប្រមុំជើងអក កាប់ក្បាលឆ្កែចចក ដកភ្លុកដំរីស» ។ អស់សត្វឮថាសំបុត្រព្រះឥន្ទ្រដូច្នោះភ័យណាស់ផ្អើលបោលជាន់គ្នា ពានលើដំរី ក្របី រមាស រមាំងៗ ស្ទុះបោលទៅជាន់លើពស់ថ្លាន់ជាទំនប់ ដាច់ខ្លួនជាពីរជាបីកំណាត់ ធ្លាយទំនប់លិចទឹកស្លាប់អស់ ។ សត្វទាំងនោះក៏ទៅជាចំណីត្រីវិញ។ តាំងពីថ្ងៃនោះមកអស់សត្វទាំងពួងកោតខ្លាចប្រាជ្ញាសុភាទន្សាយ ទុកសុភាទន្សាយជាគ្រូបាអាចារ្យទាំងអស់

**អណ្តាតជាអាទិកន្លង ស្លាប់ផង រស់ផង ពីព្រោះអណ្តាត។**